*រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ១១៩ សសរ.

## ស្តីពីការផ្ទេរសិទ្ធិ

### រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើររបស់ឯកឧត្តម ទ៉ុច ជីមហ៊ុយ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា

### សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជំនួស ឯកឧត្តម ទ៉ុច ជីមហ៊ុយ រដ្ឋលេខាធិការក្រសួងអប់រំយុវជន និង កីឡា ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ច នៅបរទេស ចាប់ពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃ ដែលឯកឧត្តម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា វិលត្រឡប់មកវិញ ។

**ប្រការ ២ :** សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ

គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះ ក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារៈកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

# II ការងារបណ្តាក្រសួង

## ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ប្រកាស

### ប្រកាសលេខ ១៣៦ បង .ប្រក ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៤

### ស្តីពីការតែងតាំង បជិគ្គាហកៈ មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍

រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ម ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើនៅ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤